# ចំណាកស្រុក ប្រាក់ផ្ញើទៅផ្ទះ និងការកាត់បន្ថយភាពក្រីក្រ៖ ភស្តុតាងពីកម្ពុជា[១]

ខ្លឹមសារសង្ខេប៖ ការសិក្សានេះ ប្រើប្រាស់ទិន្នន័យអង្កេតគ្រួសារមានលក្ខណៈតំណាងឲ្យទូទាំងប្រទេស អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៧ ដើម្បីពិនិត្យពីផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះមានប្រភពពីក្នុង និងក្រៅប្រទេស ទៅលើភាពក្រីក្រ ដោយប្រើប្រាស់ផលធៀបនៃភាពក្រីក្រ គម្លាតភាពក្រីក្រ និងគម្លាតភាពក្រីក្រលើកជាការ៉េ (squared poverty gap)។ លទ្ធផលអង្កេតបង្ហាញថា ទាំងប្រាក់ផ្ញើពីក្នុង និងក្រៅប្រទេស ជួយកាត់បន្ថយទំហំ កម្រិត និងលក្ខណៈធ្ងន់ធ្ងរនៃភាពក្រីក្រ។ ប្រាក់ផ្ញើទៅផ្ទះ ជះឥទ្ធិពលទៅលើលក្ខណៈធ្ងន់ធ្ងរនៃភាពក្រីក្រ ខ្លាំងជាងទៅលើអត្រានៃភាពក្រីក្រ។ លទ្ធផលស្រាវជ្រាវនេះ បង្ហាញថា ប្រាក់ផ្ញើទៅផ្ទះរបស់ជនចំណាកស្រុកទៅក្រៅប្រទេស មានប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ ខ្លាំងជាងប្រាក់ផ្ញើទៅផ្ទះរបស់ជនចំណាកស្រុកក្នុងប្រទេស។

## សេចក្ដីផ្ដើម

ចំណាកស្រុកនៅកម្ពុជា ភាគច្រើនជាចំណាកស្រុកក្នុងប្រទេស។ វិទ្យាស្ថានជាតិស្ថិតិ (2004) បានឲ្យដឹងថា ៣៥% នៃប្រជាជនសរុប ជាជនចំណាកស្រុកក្នុងប្រទេស ដែលខ្ពស់ជាងអត្រាក្នុងឆ្នាំ១៩៩៨ ដល់ទៅ ៤ឯកតាភាគរយ។ យុវជនដែលមានអាយុពី១៥-២៥ឆ្នាំ តំណាងឲ្យ ១៨% នៃប្រជាជនសរុប ប៉ុន្តែរួមចំណែកដល់ទៅ ៣០% នៃជនចំណាកស្រុក។

ទីដៅនៅបរទេសចម្បងរបស់ជនចំណាកស្រុកកម្ពុជា គឺប្រទេសថៃ។ ជនចំណាកស្រុកទៅថៃប្រមាណ ៩០% ជាជនចំណាកស្រុកមិនស្របច្បាប់ (គ្មានឯកសារត្រឹមត្រូវ)។ ទោះជាមានអនុស្សរណៈយោគយល់ស្ដីពី ពលករចំណាកស្រុកដែលរដ្ឋាភិបាលថៃ និងកម្ពុជា បានចុះហត្ថលេខាកាលពីឆ្នាំ២០០៣ ក្ដី ក៏ចំនួនជនចំណាកស្រុកមិនស្របច្បាប់ មិនទំនងជាធ្លាក់ចុះនោះទេ ដោយសារការចំណាយខ្ពស់ទៅលើទីភ្នាក់ងារជ្រើសរើសពលករ ទិដ្ឋាការ និងការចុះបញ្ជី (Chan 2009a)។ ម៉ាឡេស៊ី និងសាធារណៈរដ្ឋកូរ៉េ ក៏ជាគោលដៅចម្បងណាស់ដែរ។ ទីភ្នាក់ងារជ្រើសរើសពលករឯកជន ជាអ្នករៀបចំសម្រួលការធ្វើចំណាកស្រុកទៅប្រទេសទាំងពីរនេះ។ ពលករចំណាកស្រុកកម្ពុជាទៅម៉ាឡេស៊ីភាគច្រើន មានឯកសារត្រឹមត្រូវ ប៉ុន្តែក្រោយមកជាច្រើននាក់ក៏បានបាត់បង់ភាពស្របច្បាប់។ ពលករចំណាកស្រុកកម្ពុជាទាំងអស់ដែលធ្វើការនៅសាធារណៈរដ្ឋកូរ៉េ ជាពលករស្របច្បាប់ (Maltoni 2007)។ ពលករចំណាកស្រុកកម្ពុជាក៏មានទៅធ្វើការនៅហុងកុង តៃវ៉ាន់ អារ៉ាប៊ីសាអ៊ូឌីត និងកាតា ដែរ ប៉ុន្តែពុំទាន់មានតួលេខច្បាស់នៃប្រជាជនកម្ពុជាទាំងអស់ដែលរស់នៅ និងធ្វើការនៅទីនោះទេ។

យោងតាម Ratha and Mohapatra (2009) ប្រាក់ផ្ញើជាផ្លូវការពីក្រៅប្រទេស មានដល់ ៣២៥លានដុល្លារ ក្នុងឆ្នាំ២០០៨ ដែលខ្ពស់ជាងប្រាក់ផ្ញើកាលពី ១០ឆ្នាំមុន ប្រមាណ៣ដង។ ទំហំនៃប្រាក់ផ្ញើទៅផ្ទះជាផ្លូវការពីបរទេស បានកើនឡើង ប៉ុន្តែមានការយកចិត្តទុកដាក់តិចតួចនៅឡើយ អំពីផលប៉ះពាល់ខាងសេដ្ឋកិច្ចនៃការផ្ទេរប្រាក់នេះ មកលើសេដ្ឋកិច្ចគ្រួសារ។ ការសិក្សានេះ ព្យាយាមធ្វើការវាស់វែងពីឥទ្ធិពលនៃប្រាក់ផ្ញើទៅផ្ទះ មកពីបរទេស និងពីក្នុងប្រទេស ទៅលើភាពក្រីក្រ។

## ទិន្នន័យ និងលទ្ធផលរកឃើញជាក់ស្ដែង

ការសិក្សានេះ បានប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៧ ដែលប្រមូលដោយវិទ្យាស្ថានជាតិស្ថិតិ។ អង្កេតនេះ មានលក្ខណៈតំណាងឲ្យទូទាំងប្រទេស ព្រោះបានធ្វើអង្កេតលើ ៣៥៩៣គ្រួសារ ក្នុងនោះមាន ២២២៨គ្រួសារនៅជនបទ។ អង្កេតនេះ ផ្ដល់ព័ត៌មានលំអិតជាច្រើន រួមមាន លក្ខណៈគ្រួសារ ការចំណាយលើអាហារ និងទំនិញមិនមែនអាហារ ទ្រព្យជាប់លាប់ សត្វចិញ្ចឹម ផលិតកម្មកសិកម្មគ្រួសារ ការប្រមូលអនុផលព្រៃឈើ ផលិតកម្មមិនមែន កសិកម្មផ្សេងទៀត ការងារមានប្រាក់ខែ និងប្រាក់ផ្ញើទៅផ្ទះ។

ទោះយ៉ាងនេះក្ដី CSES នេះ មិនមែនរៀបចំឡើងជាអង្កេតលើចំណាកស្រុក ឬប្រាក់ផ្ញើទៅផ្ទះនោះទេ ដូច្នេះក៏គ្មានការប្រមូលព័ត៌មាន អំពីលក្ខណៈសំគាល់របស់ជនចំណាកស្រុក ដូចជា អាយុ ការអប់រំ ឬប្រាក់ចំណូលរកបាននៅឆ្ងាយពីផ្ទះនោះដែរ។ ក្នុងអង្កេតនេះ មានតែ ២សំណួរប៉ុណ្ណោះ ដែលទាក់ទិននឹងប្រាក់ផ្ញើទៅផ្ទះ៖ (១) ក្នុងរយៈពេល១២ខែចុងក្រោយនេះ តើគ្រួសាររបស់អ្នកទទួលបានប្រាក់ផ្ញើក្នុងស្រុកចំនួនប៉ុន្មានពីសាច់ញាតិ និងអ្នកផ្សេងទៀត? (២) ក្នុងរយៈពេល ១២ខែចុងក្រោយនេះ តើគ្រួសាររបស់អ្នកទទួលបានប្រាក់ផ្ញើពីបរទេសចំនួនប៉ុន្មានពីសាច់ញាតិ និងអ្នកផ្សេងទៀត? ទោះយ៉ាងនេះក្ដី ព័ត៌មានពីចំណូល និងចំណាយរបស់គ្រួសារ អាចឲ្យយើងកំណត់បានពីផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះទៅលើភាពក្រីក្រ។

តារាង១ បង្ហាញថា មាន ២៧៤៣គ្រួសារ (៧៦,៣% នៃគ្រួសារគំរូតាងសរុប) មិនបានទទួលប្រាក់ផ្ញើទៅផ្ទះទេ ហើយ ៧១៤គ្រួសារ (១៩,៩%) ទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និង ១៥៣គ្រួសារ (៤,៣%) ទទួលបានប្រាក់ផ្ញើពីបរទេស។ ក្នុងចំណោមគ្រួសារទទួលបានប្រាក់ផ្ញើទៅផ្ទះ មានតែ ១៧គ្រួសារប៉ុណ្ណោះ ដែលទទួលបានទាំងប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស។

---

១ អត្ថបទនេះ រៀបរៀងដោយ លោក តុង គឹមស៊ុន ជាអ្នកស្រាវជ្រាវ និងជាអ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ បណ្ឌិត Hossein Jalilian និងអ្នកកែសម្រួលមកពីខាងក្រៅវិទ្យាស្ថាន ដែលបានជួយផ្ដល់មតិលើអត្ថបទព្រាងពីដំបូង។

តារាង ១៖ ប្រភពប្រាក់ចំណូលសម្រាប់គ្រួសារបានទទួល និងមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ (រៀល/នាក់/ថ្ងៃ)

| ប្រភព | មិនបានទទួលប្រាក់ផ្ញើទៅផ្ទះ | ទទួលប្រាក់ផ្ញើពីក្នុងស្រុក | ទទួលប្រាក់ផ្ញើពីបរទេស |
|---|---|---|---|
| សត្វចិញ្ចឹម | 328.47<br>(2101.15) | 591.92<br>(2077.98) | 240.33<br>(684.80) |
| នេសាទ | 113.21<br>(539.31) | 90.89<br>(579.86) | 60.43<br>(199.48) |
| ព្រៃឈើ | 136.06<br>(372.37) | 146.60<br>(207.08) | 92.83<br>(247.66) |
| ផលិតកម្មមិនមែនកសិកម្ម | 2197.09<br>(19,762.08) | 1852.08<br>(26,091.79) | 2820.01<br>(8029.68) |
| ប្រាក់ផ្ញើពីក្នុងស្រុក | 0 | 619.48<br>(1366.47) | 86.06<br>(373.34) |
| ប្រាក់ផ្ញើពីបរទេស | 0 | 23.438<br>(254.82) | 1938.62<br>(3167.31) |
| បៀវត្សរ៍ | 1807.89<br>(6009.99) | 1686.81<br>(4229.51) | 3775.56<br>(14,941.30) |
| ផលិតកម្មផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់ | 52.81<br>(69.74) | 66.13<br>(75.39) | 59.22<br>(121.76) |
| ផ្សេងៗ | 336.08<br>(3225.52) | 566.55<br>(10711.07) | 426.39<br>(1947.11) |
| ប្រាក់ចំណូលសរុប | 4971.61<br>(21,116.23) | 5643.93<br>(28,543.99) | 9499.50<br>(17,364.90) |
| គំរូតាង | 2743 | 714 | 153 |

*សម្គាល់៖ គំលាតស្តង់ដា (Standard deviations) មានបង្ហាញនៅក្នុងរង្វង់ក្រចក។*
*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

ប្រាក់ផ្ញើពីក្នុងស្រុក មានចំណែក ២,៣% និង ពីបរទេសមាន ១,៦% នៅក្នុងប្រាក់ចំណូលសុទ្ធរបស់គ្រួសារគំរូតាងទាំងអស់។ ប្រាក់ផ្ញើពីក្នុងស្រុក មាន ១០,៩% និងពីបរទេសមាន ០,៤% នៅក្នុងប្រាក់ចំណូលសុទ្ធសរុបនៃ ៧១៤គ្រួសារដែលទទួលបានប្រាក់ផ្ញើពីក្នុងស្រុក។ សម្រាប់ ១៥៣គ្រួសារដែលទទួលបានប្រាក់ផ្ញើពីបរទេស ប្រាក់នេះមានចំណែក ២០,៤% នៅក្នុងប្រាក់ចំណូលសុទ្ធសរុប រីឯប្រាក់ផ្ញើពីក្នុងស្រុកមានត្រឹម ០,៩%។ ជាមធ្យម ក្នុងឆ្នាំ២០០៧ ប្រាក់ផ្ញើទៅផ្ទះសម្រាប់គ្រួសារទទួលប្រាក់ផ្ញើពីក្នុងស្រុក មានចំនួន ៦២០រៀល/នាក់/ថ្ងៃ ហើយសម្រាប់គ្រួសារទទួលប្រាក់ផ្ញើពីបរទេសគឺ ១៩៤០រៀលនាក់/ថ្ងៃ។ តួលេខនេះគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ពីព្រោះពលករនៅបរទេសអាចរកប្រាក់បានច្រើនជាងពលករនៅកម្ពុជា។

តារាង ១ បង្ហាញទៀតថា គ្រួសារមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ មានប្រាក់ចំណូលតិចជាង គ្រួសារដែលទទួលប្រាក់ផ្ញើពីក្នុងស្រុក/ពីបរទេស។ ប៉ុន្តែការប្រៀបធៀបបែបសាមញ្ញនេះ អាចមានការខុសឆ្គង ពីព្រោះគេមិនដឹងពីចំណូលដែលគ្រួសារ ទទួលប្រាក់ផ្ញើទៅផ្ទះអាចរកបាន ប្រសិនបើជនចំណាកស្រុកបានជ្រើសយកការស្នាក់នៅ និងធ្វើការក្នុងស្រុកវិញ។ ដើម្បីដោះស្រាយបញ្ហាចោទខាងវិធីសាស្ត្រនេះ យើងបានអនុវត្តតាមនីតិវិធីរបស់ Adams (2004) ដែលចង្អុលបង្ហាញថា ការប៉ាន់ស្មានពីស្ថានភាពផ្ទុយពីហេតុការណ៍ជាក់ស្តែង គឺជាការចាំបាច់ ហើយលទ្ធផលអាចប្រើជាមូលដ្ឋាន សម្រាប់វាយតម្លៃពីផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះទៅលើភាពក្រីក្រ។ ដើម្បីអនុវត្តវិធីសាស្ត្រនេះ ជាដំបូង ត្រូវកំណត់រកប៉ារ៉ាម៉ែត្រសម្រាប់ប៉ាន់ស្មានពីប្រាក់ចំណូលក្នុងមនុស្សម្នាក់ ដោយយកប្រជាជនទាំង ២៧៤៣គ្រួសារដែលមិនទទួលបានប្រាក់ផ្ញើទៅផ្ទះ ធ្វើជាមូលដ្ឋាន។ បន្ទាប់មកត្រូវយកប៉ារ៉ាម៉ែតទាំងនេះ ទៅអនុវត្តលើ ៨៦៧គ្រួសារដែលទទួលបានប្រាក់ផ្ញើទៅផ្ទះ។ សមីការបានយកមកប្រើដើម្បីប៉ាន់ស្មានពីប៉ារ៉ាម៉ែត្រ៖

$$Y_i = aX + \varepsilon_i \qquad (១)$$

ក្នុងនេះ $Y_i$ ជាប្រាក់ចំណូលរបស់មនុស្សម្នាក់ក្នុងគ្រួសារ $i$, $X_i$ ជាវ៉ិចទ័រនៃលក្ខណៈសំគាល់គ្រួសារ $i$, $a$ ជាវ៉ិចទ័រមេគុណត្រូវធ្វើការប៉ាន់ស្មាន ហើយ $\varepsilon_i$ ជាកត្តាលំអៀង។

ទោះយ៉ាងនេះក្តី Adams (2004) បានកត់សម្គាល់ថា ការកំណត់ឲ្យច្បាស់ថា អថេរណាខ្លះជាកត្តាពីខាងក្រៅសម្រាប់ប្រាក់ចំណូល (ឬចំណាយ) របស់គ្រួសារ វាលំបាក និងស្មុគស្មាញ

ណាស់។ ដូច្នេះបញ្ហាខាងសេដ្ឋមាត្រដ៏សំខាន់ សម្រាប់ការគណនាសមីការ (១) គឺការជ្រើសរើសអថេរ។ យើងបានផ្ដល់សម្មតិកម្មថាប្រាក់ចំណូល (ឬចំណាយ) ក្នុងមនុស្សម្នាក់ អាចប៉ាន់ស្មានជាមុខងារនៃលក្ខណៈសំគាល់របស់មេគ្រួសារ (ការអប់រំ អាយុ យេនឌ័រ) និងលក្ខណៈសំគាល់នៃគ្រួសារ (អថេរជាដីកសិកម្ម លក្ខណៈលំនៅឋាន តំបន់ និងជនជាតិ)៖

$$Y_i = \alpha_0 + \alpha_1 HHHAge_i + \alpha_2 HHHGender_i + \alpha_3 HHSize_i + \alpha_4 EDUMale_i + \alpha_5 EDUFemale_i + \alpha_6 Room_i + \alpha_7 Light_i + \alpha_8 Water_i + \alpha_9 Agr_Land_i + \alpha_{10} Rural_i + \alpha_{11} Urban_i + \varepsilon_i \quad (២)$$

ក្នុងនេះ $Y$ ជាប្រាក់ចំណូលគ្រួសារ (ឬចំណាយ) ក្នុងមនុស្សម្នាក់ *HHHAge* ជាអាយុរបស់មេគ្រួសារ *HHHGender* ជាយែនឌ័ររបស់មេគ្រួសារ *HHSize* ជាចំនួនសមាជិកគ្រួសារ *EDUMale* ជាកម្រិតអប់រំមធ្យមរបស់សមាជិកគ្រួសារជាបុរសអាយុលើសពី ១៨ឆ្នាំ *EDUFemale* ជាកម្រិតអប់រំមធ្យមរបស់សមាជិកគ្រួសារជានារីអាយុលើសពី ១៨ឆ្នាំ *Room* ជាចំនួនបន្ទប់ក្នុងគ្រួសារ *Light* ជាប្រភពបំភ្លឺ *Agr_Land* ជាដីកសិកម្ម ហើយ *Rural* និង *Urban* ជាអថេរ បញ្ជាក់ពីតំបន់។ យើងប្រើវិធីសាស្ត្រ *ordinary least squares* ដើម្បីគណនាសមីការ (២)។ ដោយសារតែការសិក្សានេះ សំដៅប៉ាន់ស្មានពីផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះ ទៅលើភាពក្រីក្រ ហើយឯកសារវិភាគពីភាពក្រីក្រទាំងអស់នៅកម្ពុជា សុទ្ធតែប្រើចំណាយប្រើប្រាស់ ធ្វើជាសូចនាករ ដើម្បីវាស់វែងអំពីចំនួនជនក្រីក្រ គម្លាតភាពក្រីក្រ និងគម្លាតភាពក្រីក្រលើកជាការ៉េ ដូច្នេះទើបត្រូវយកចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ មកប្រើជាអថេរប្រែប្រួលរបស់សមីការ (២)។

ដូចបានបង្ហាញក្នុងតារាង ២ អថេរឯករាជ្យដែលបានជ្រើសរើសមួយចំនួន មានភាពខុសប្លែកគ្នាខាងស្ថិតិរវាងគ្រួសារទទួល និងមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ ខណៈដែលអថេរខ្លះទៀត មានលក្ខណៈស្រដៀងគ្នា។ គ្រួសារទទួលបានប្រាក់ផ្ញើទៅផ្ទះ ច្រើនតែមានមេគ្រួសារជាស្ត្រី និងមានវ័យចំណាស់ជាង មានទំហំគ្រួសារតូចជាង មានបន្ទប់ច្រើនជាងក្នុងផ្ទះ មានអគ្គិសនីប្រើតិចជាង និងរស់នៅតំបន់ជនបទច្រើនជាង គ្រួសារមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ។ ការអប់រំនៃសមាជិកប្រុសស្រី ប្រភពទឹកបរិភោគ ឬការកាន់កាប់ដីកសិកម្ម មិនមានភាពខុសប្លែកគ្នាទេ រវាងគ្រួសារទាំងពីរក្រុម។ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវជាក់ស្ដែងទាំងនេះ យើងធ្វើការប៉ាន់ស្មានពីចំណាយប្រើប្រាស់គិតក្នុងសមាជិកគ្រួសារមួយនាក់ របស់ក្រុមទាំងពីរ សម្រាប់ពីរករណី៖ (a) អថេរឯករាជ្យជ្រើសរើសដែលមិនមានភាពខុសប្លែកគ្នាខាងស្ថិតិរវាងក្រុមទាំងពីរ និង (b) អថេរឯករាជ្យជ្រើសរើសទាំងអស់។ យើងផ្ដោតលើគំរូ b សម្រាប់ការបកស្រាយបន្ថែមទៀត។

**តារាង ២៖ ទិន្នន័យសង្ខេបអំពីគ្រួសារបានទទួល និងមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ**

| អថេរ | មិនបានទទួល ប្រាក់ផ្ញើទៅផ្ទះ | បានទទួលប្រាក់ផ្ញើទៅផ្ទះ | t-test |
|---|---|---|---|
| ភេទរបស់មេគ្រួសារ (១=បុរស, 0=នារី) | 0.80 (0.39) | 0.65 (0.47) | 9.09*** |
| អាយុមេគ្រួសារ (ឆ្នាំ) | 43.83 (12.73) | 52.31 (13.89) | -16.47*** |
| ទំហំគ្រួសារ (នាក់) | 4.93 (1.97) | 4.58 (2.05) | 4.47*** |
| កម្រិតការអប់រំមធ្យម(mean)របស់បុរសពេញវ័យ (ឆ្នាំ) | 5.90 (4.10) | 5.65 (4.18) | 1.55 |
| កម្រិតការអប់រំមធ្យម(mean)របស់នារីពេញវ័យ (ឆ្នាំ) | 4.36 (3.42) | 4.16 (3.42) | 1.44 |
| ចំនួនបន្ទប់ក្នុងផ្ទះ | 1.48 (0.94) | 1.58 (1.11) | -2.50** |
| ភ្លើងបំភ្លឺ(១=អគ្គិសនី, 0=ផ្សេងពីនេះ) | 0.36 (0.48) | 0.32 (0.47) | 2.01** |
| ប្រភពទឹកបរិភោគ (១=ទឹកម៉ាស៊ីន, 0=ផ្សេងពីនេះ) | 0.25 (0.43) | 0.24 (0.43) | 0.12 |
| ដីកសិកម្ម (១=មានដីកសិកម្ម, 0=ផ្សេងពីនេះ) | 0.60 (0.48) | 0.64 (0.47) | -1.88 |
| ជនបទ (១= ជនបទ, 0= ផ្សេងពីនេះ) | 0.61 (0.48) | 0.65 (0.47) | -2.09** |

*គម្លាតស្តង់ដា (Standard deviations)៖ លេខក្នុងរង្វង់ក្រចក។*
** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត 0,១។ ** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត0,0៥។ *** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត 0,0១។*
*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

តារាង ៣៖ ការប៉ាន់ស្មានពីចំណាយប្រើប្រាស់ក្នុងសមាជិកគ្រួសារ១នាក់ (មិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ)

| | គំរូ a | គំរូ b |
|---|---|---|
| កម្រិតអប់រំមធ្យម (mean) របស់បុរសពេញវ័យ | 0.006*** | 0.006*** |
| កម្រិតអប់រំមធ្យម (mean) របស់នារីពេញវ័យ | 0.004*** | 0.004*** |
| ទឹកហូប (១=ទឹកម៉ាស៊ីន, 0=ផ្សេងពីនេះ) | 0.122*** | 0.100*** |
| ដីកសិកម្ម (១=មានដីកសិកម្ម, 0=ផ្សេងពីនេះ) | -0.007 | 0.001 |
| ជនបទ | -1.125*** | -1.059*** |
| ទីប្រជុំជន | -0.719*** | -0.683*** |
| ភេទរបស់មេគ្រួសារ (១=បុរស, 0=នារី) | | 0.005 |
| អាយុមេគ្រួសារ (ឆ្នាំ) | | 0.001*** |
| ទំហំគ្រួសារ | | -0.019*** |
| ចំនួនបន្ទប់ក្នុងផ្ទះ | | 0.041*** |
| ភ្លើងបំភ្លឺ (១=អគ្គិសនី, 0=ផ្សេងពីនេះ) | | 0.063*** |
| បញ្ចភាគ ២ | 0.408*** | 0.391*** |
| បញ្ចភាគ ៣ | 0.688*** | 0.662*** |
| បញ្ចភាគ ៤ | 0.992*** | 0.948*** |
| បញ្ចភាគ ៥ | 1.573*** | 1.493*** |
| ថេរ | 8.409*** | 8.351*** |
| Adjust R-squared | 0.915 | 0.918 |
| ទំហំគំរូតាង | 2743 | 2743 |

** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត 0,១។ ** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត 0,0៥។ *** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត 0,0១។*
*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

តារាង ៣ សង្ខេបពីលទ្ធផលទទួលបានពីការប្រើសមីការ (២) ដើម្បីប៉ាន់ស្មានពីចំណាយប្រើប្រាស់ គិតក្នុងសមាជិកគ្រួសារមួយនាក់ ដោយមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ។ មេគុណទាំងអស់មានភាពខុសប្លែកគ្នាគួរកត់សំគាល់ខាងស្ថិតិនៅកម្រិត ១% លើកលែងអថេរមួយដែលវាស់វែងពីយេនឌ័ររបស់មេគ្រួសារ។ មេគុណទាំងនេះ អាចយកមកប្រើ ដើម្បីប៉ាន់ស្មានពីចំណាយប្រើប្រាស់គិតក្នុងសមាជិកគ្រួសារមួយនាក់ ក្នុងស្ថានភាពមួយដែលមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ ទាំងសម្រាប់គ្រួសារមិនទទួលបានប្រាក់ផ្ញើទៅផ្ទះ គ្រួសារទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និងគ្រួសារទទួលបានប្រាក់ផ្ញើពីបរទេស។ ក្រោយពេលគណនាឃើញចំណាយប្រើប្រាស់ក្នុងសមាជិកគ្រួសារមួយនាក់ ដោយមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះនោះហើយ ចំណាយប្រើប្រាស់ក្នុងសមាជិកគ្រួសារមួយនាក់ ដែលគិតបញ្ចូលទាំងប្រាក់ផ្ញើទៅផ្ទះ អាចគណនាបានដោយបន្ថែម ៨០% នៃចំនួនជាក់ស្តែងនៃប្រាក់ដែលផ្ញើទៅផ្ទះក្នុងមនុស្សម្នាក់[២]។

តារាង ៤ រាយការណ៍ពីការប៉ាន់ស្មាន ចំណាយប្រើប្រាស់ក្នុងសមាជិកគ្រួសារ១នាក់ សម្រាប់គ្រួសារទាំង៣ក្រុម ក្នុងស្ថានភាព២៖ គិតបញ្ចូល និងមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ។ បើមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ៖ ចំណាយប្រើប្រាស់ក្នុងមនុស្ស១នាក់ នៃគ្រួសារទទួលប្រាក់ផ្ញើពីក្នុងស្រុក មានកម្រិតទាបជាងគ្រួសារមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ ប្រមាណ ២-៤%។ គ្រួសារទទួលបានប្រាក់ផ្ញើពីបរទេស មានចំណាយប្រើប្រាស់ក្នុងមនុស្ស១នាក់ ខ្ពស់ជាងពីរក្រុមផ្សេងទៀត ដែលមានន័យថា គ្រួសារភាគច្រើនដែលមានជនចំណាកស្រុកទៅបរទេស ជាទូទៅមានជីវភាពធូរធារជាងគ្រួសារមានជនចំណាកស្រុកក្នុងប្រទេស និងគ្រួសារមិនមានជនចំណាកស្រុក។ នៅពេលបានគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ៖ ចំណាយប្រើប្រាស់មធ្យមក្នុងមនុស្ស១នាក់ សម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស មានកម្រិត ៦% និង ៨០% ខ្ពស់ជាងគ្រួសារមិនទទួលបានប្រាក់ផ្ញើទៅផ្ទះ។

## ប្រាក់ផ្ញើទៅផ្ទះ និងការកាត់បន្ថយភាពក្រីក្រ

ដើម្បីកំណត់ពីផលប៉ះពាល់នៃប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស ទៅលើភាពក្រីក្រ និងវិសមភាព យើងបានពិចារណាលើសេណារីយ៉ូ២។ នៅក្នុងសេណារីយ៉ូទី១ យើងប៉ាន់ស្មានអំពីអនុបាតចំនួនជនក្រីក្រ គម្លាតភាពក្រីក្រ គម្លាតភាពក្រីក្រលើកជាការ៉េ និងមេគុណ Gini ដោយមិនគិតបញ្ចូលទាំងប្រាក់ផ្ញើទៅផ្ទះ។ នៅក្នុងសេណារីយ៉ូទី២ យើងគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ។ សម្រាប់បន្ទាត់ភាពក្រីក្រ និងការវាស់វែងអំពីភាពក្រីក្រផ្សេងៗទៀត ការ

២ Chan (2009a) កត់សម្គាល់ថា ៨០-៨៧% នៃប្រាក់ផ្ញើទៅផ្ទះ ត្រូវបានចំណាយលើការប្រើប្រាស់ទំនិញ ហើយត្រឹម ១៣%-២០% ប៉ុណ្ណោះ ត្រូវបានចំណាយលើផលិតកម្ម។

តារាង ៤៖ ចំណាយប្រើប្រាស់ប៉ាន់ស្មានក្នុងមនុស្ស១នាក់ សម្រាប់គ្រួសារទទួល និងមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ ( គិតជារៀល/នាក់/ថ្ងៃ )

| | មិនទទួលបាន ប្រាក់ផ្ញើមកផ្ទះ | ទទួលបានប្រាក់ផ្ញើ ពីក្នុងស្រុក | ទទួលបានប្រាក់ផ្ញើ ពីបរទេស |
|---|---|---|---|
| គំរូ១ | | | |
| ចំណាយប្រើប្រាស់ប៉ាន់ស្មានមធ្យមមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ | 5961.05 (5548.86) | 5700.90 (5256.05) | 9503.96 (7707.83) |
| ចំណាយប្រើប្រាស់ប៉ាន់ស្មានមធ្យម គិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ | 5961.05 (5548.86) | 6193.46 (5653.87) | 11150.28 (9572.14) |
| គំរូ២ | | | |
| ចំណាយប្រើប្រាស់ប៉ាន់ស្មានមធ្យមមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ | 5975.17 (5614.18) | 5828.61 (5485.17) | 9708.99 (8050.53) |
| ចំណាយប្រើប្រាស់ប៉ាន់ស្មានមធ្យម គិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ | 5975.17 (5614.18) | 6321.17 (5867.83) | 11355.30 (9885.59) |
| គំរូតាង | 2743 | 697 | 136 |

*សម្គាល់៖ គំលាតស្តង់ដា (Standard deviations): លេខក្នុងវង់ក្រចក។*
*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ។*

គិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ វាកាត់បន្ថយនូវភាពក្រីក្រ គម្លាតភាពក្រីក្រ និងគម្លាតភាពក្រីក្រលើកជាការ៉េ។ ទំហំនៃការកាត់បន្ថយភាពក្រីក្រ គឺអាស្រ័យលើការវាស់វែង និងបន្ទាត់ភាពក្រីក្រ។ ភាពក្រីក្រក្នុង ៣៥៧៦គ្រួសារ ធៀបនឹងបន្ទាត់ភាពក្រីក្រជាតិគឺ ២៤,៣៣% បើគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ និង ២៥,៥៣% បើមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ (មានកំណើន ១,២ឯកតាភាគរយ)។ ការគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះទៅក្នុងចំណាយគ្រួសារ វាកាត់បន្ថយភាពក្រីក្របានបន្ថែមទៀត សម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើទៅផ្ទះ។ តារាង៥ បង្ហាញថា ប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស បានធ្វើឲ្យកម្រិតភាពក្រីក្រធ្លាក់ចុះ ៤,៧៣ និង ៧,៣៥ឯកតាភាគរយ។ ប៉ុន្តែភាពក្រីក្រត្រូវថយចុះកាន់តែច្រើន នៅពេលយើងវាស់វែង ដោយប្រើគម្លាតភាពក្រីក្រ និង គម្លាតភាពក្រីក្រលើកជាការ៉េ។ ឧទាហរណ៍ ការវាស់ដោយប្រើគម្លាតភាពក្រីក្រលើកជាការ៉េ បង្ហាញថា ប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស

តារាង ៥៖ ផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះទៅលើភាពក្រីក្រ ក្នុងគ្រួសារបានទទួល និងមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ

| បន្ទាត់ភាពក្រីក្រជាតិ | | | | | | |
|---|---|---|---|---|---|---|
| | គ្រួសារទាំងអស់ | | គ្រួសារទទួលបានប្រាក់ផ្ញើ ពីក្នុងស្រុក | | គ្រួសារទទួលបានប្រាក់ផ្ញើ ពីបរទេស | |
| | មិនបានទទួល ប្រាក់ផ្ញើទៅផ្ទះ | គិតបញ្ចូលប្រាក់ ផ្ញើពីក្នុងស្រុក និងពីបរទេស | មិនបានទទួល ប្រាក់ផ្ញើទៅផ្ទះ | គិតបញ្ចូលប្រាក់ ផ្ញើពីក្នុងស្រុក | មិនបានទទួល ប្រាក់ផ្ញើទៅផ្ទះ | គិតបញ្ចូលប្រាក់ ផ្ញើពីបរទេស |
| គំរូ១ | | | | | | |
| ចំនួនជនក្រីក្រ (%) | 27.27 | 25.76 | 28.69 | 22.38 | 13.24 | 5.88 |
| គម្លាតភាពក្រីក្រ (%) | 5.60 | 5.30 | 5.36 | 4.10 | 2.62 | 1.11 |
| គម្លាតភាពក្រីក្រលើកជាការ៉េ (%) | 1.79 | 1.67 | 1.67 | 1.20 | 0.84 | 0.31 |
| មេគុណ Gini | 0.43 | 0.44 | 0.42 | 0.43 | 0.43 | 0.44 |
| គំរូតាង | 3576 | 3576 | 697 | 697 | 136 | 136 |
| គំរូ២ | | | | | | |
| ចំនួនជនក្រីក្រ (%) | 25.53 | 24.33 | 24.39 | 19.66 | 12.50 | 5.15 |
| គម្លាតភាពក្រីក្រ (%) | 5.54 | 5.28 | 5.05 | 3.98 | 2.45 | 1.07 |
| គម្លាតភាពក្រីក្រលើកជាការ៉េ (%) | 1.77 | 1.67 | 1.59 | 1.16 | 0.77 | 0.30 |
| មេគុណ Gini | 0.43 | 0.44 | 0.42 | 0.43 | 0.43 | 0.44 |
| គំរូតាង | 3576 | 3576 | 697 | 697 | 136 | 136 |

*សម្គាល់៖ គ្រួសារទទួលបានទាំងប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស ត្រូវបានដកចេញ។*
*ប្រភព៖ ការគណនារបស់អ្នកនិពន្ធពី CSES 2007*

អាចកាត់បន្ថយភាពក្រីក្របាន ៥,៧% សម្រាប់គ្រួសារជាគំរូតាងទាំង ៣៥៧៦គ្រួសារ ២៦,៩% សម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និង ៦០,៨% សម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើពីបរទេស។ លទ្ធផលនេះមានន័យថា ប្រាក់ផ្ញើទៅផ្ទះវាកាត់បន្ថយកម្រិតធ្ងន់ធ្ងរនៃភាពក្រីក្រ បានច្រើនជាងចំនួនភាគរយអ្នករស់នៅក្នុងភាពក្រីក្រ។ លទ្ធផលសិក្សានេះ មិនមានការផ្លាស់ប្ដូរទេ នៅពេលបន្ទាត់ភាពក្រីក្រអន្តរជាតិ ត្រូវបានយកមកប្រើប្រាស់ បើទោះជាការកាត់បន្ថយភាពក្រីក្រមានទំហំតូចជាងក្ដី។

តារាង ៥ ក៏បានបង្ហាញថា ប្រាក់ផ្ញើពីក្នុងស្រុក ឬពីបរទេស មានផលប៉ះពាល់តិចលើវិសមភាពចំណាយប្រើប្រាស់ (ប្រាក់ចំណូល) ដែលវាស់វែងតាមមេគុណ Gini។ ចំណុចនេះបង្ហាញថា ឥទ្ធិពលនៃប្រាក់ផ្ញើទៅផ្ទះលើការកាត់បន្ថយភាពក្រីក្រ ភាគច្រើនកើតមានដោយសារកំណើនប្រាក់ចំណូលគ្រួសារមធ្យម ជាជាងការប្រែប្រួលនៃវិសមភាពប្រាក់ចំណូល។

## សេចក្ដីសន្និដ្ឋាន

អត្ថបទនេះ បានប្រើប្រាស់អង្កេតលើ ៣៥៩៣នៃគ្រួសារដែលមានលក្ខណៈតំណាងឲ្យទូទាំងប្រទេស និងធ្វើការប៉ាន់ស្មានមុខងារប្រាក់ចំណូល ដើម្បីវិភាគពីផលប៉ះពាល់នៃប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស ទៅលើភាពក្រីក្រ និងវិសមភាព។ ការសិក្សាបានរកឃើញថា មានគ្រួសារតិចជាង ២៤% ទទួលបានប្រាក់ផ្ញើទៅផ្ទះ ដោយក្នុងនោះ ១៩,៩% ទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និង ៤,៣% ទទួលប្រាក់ផ្ញើពីបរទេស។ ប្រាក់ផ្ញើទៅផ្ទះ រួមចំណែក ១១% ក្នុងប្រាក់ចំណូលសរុបសម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និង ២០% សម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើពីបរទេស។ ប្រាក់ផ្ញើទៅផ្ទះទាំងពីរប្រភេទ ជួយកាត់បន្ថយកម្រិត ជម្រៅ និងលក្ខណៈធ្ងន់ធ្ងរនៃភាពក្រីក្រ។ ទំហំនៃការកាត់បន្ថយភាពក្រីក្រ អាស្រ័យលើវិធីវាស់វែងភាពក្រីក្រ។ នៅពេលប្រើបន្ទាត់ភាពក្រីក្រជាតិ ភាពក្រីក្របានថយចុះប្រមាណ ១ឯកតាភាគរយ ដោយសារប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស។ ប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស អាចកាត់បន្ថយអត្រាក្រីក្របាន ៤,៧៣ និង ៧,៣៥ឯកតាភាគរយរៀងគ្នា។ ប៉ុន្តែតួលេខភាពក្រីក្រត្រូវថយចុះកាន់តែច្រើន នៅពេលយើងវាស់វែងដោយប្រើគម្លាតភាពក្រីក្រ ឬគម្លាតភាពក្រីក្រលើកជាការ៉េ ហើយចំណុចនេះបង្ហាញថា ប្រាក់ផ្ញើទៅផ្ទះមានផលប៉ះពាល់លើកម្រិតធ្ងន់ធ្ងរនៃភាពក្រីក្រ ខ្លាំងជាងលើចំនួនអ្នករស់នៅក្នុងភាពក្រីក្រ។ ការសិក្សានេះក៏បង្ហាញដែរថា ប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស មានផលប៉ះពាល់តិចតួចទៅលើវិសមភាព ដែលមានន័យថា ការកាត់បន្ថយភាពក្រីក្រ កើតមានជាសំខាន់ដោយសារកំណើននៃប្រាក់ចំណូលមធ្យម។

## ឯកសារយោង


Adams, Richard Jr. (1991), "The Economic Uses and Impact of International Remittances in Rural Egypt", *Economic Development and Cultural Changes*, Vol. 39, No. 4, pp.695-722

Adams, Richard Jr. (1993), "The Economic and Demographic Determinants of International Migration in Rural Egypt", *Journal of Development Studies*, Vol.30, No.1, October, pp. 146-167

Adams, Richard Jr. (2004), *Remittances and Poverty in Guatemala*, Policy Research Working Paper 3418 (Washington, DC: World Bank)

Adams, Richard Jr. (2005a), "Remittances, Selection Bias and Poverty in Guatemala", unpublished manuscript (Washington, DC: World Bank)

Adams, Richard Jr. (2005b), *Remittances, Household Expenditure and Investment in Guatemala.* Policy Research Working Paper 3532 (Washington, DC: World Bank)

Adams, Richard Jr. & John Page (2005), "Do International Migration and Remittances Reduce Poverty in Developing Countries?", *World Development*, 33, pp. 1645-1669

Bauer, Amin, Rana Hasan, Rhoda Magsombol & Guanghua Wan (2008), *The World Bank's New Poverty Data: Implications for the Asian Development Bank*, ADB Sustainable Development Working Paper Series No.2 (Manila: ADB)

Chan, Sophal (2009a), *Economic Costs and Benefits of Cross-Border Labour Migration in the GMS: Cambodia Country Study* (Phnom Penh: CDRI)

Chan, Sophal (2009b), *Review of Labour Migration Management, Policies and Legal Framework in Cambodia* (Bangkok: International Labour Organization Regional Office for Asia and the Pacific)

Chami, Ralph, Connel Fullenkamp & Samir Jahjah (2003), *Are Immigrant Remittance Flows a Source of Capital for Development?*, International Monetary Fund Working Paper 03/189 (Washington, DC: IMF)

Edwards, Alejandra & Manuelita Ureta (2003), "International Migration, Remittances and Schooling: Evidence from El Salvador", *Journal of Development Economics*, 72, pp. 429-461

Lim Sovannara (2007), *Youth Migration and Urbanisation in Cambodia*, Working Paper 36 (Phnom Penh: CDRI)

Maltoni, Bruno (2006), *Impact of Remittances on Local Communities in Cambodia: The Case of Prey Veng Province* (Phnom Penh: International Organisation for Migration).

Maltoni, Bruno (2007), *Migration in Cambodia: Internal vs. External Flows*, mimeographed (Phnom Penh)

National Institute of Statistics (2004), *Statistical Yearbook* (Phnom Penh: Ministry of Planning)

Ratha Dilip & Mohapatra (2009), "Outlook for Remittances Flows 2009-2011: Remittances expected to fall by 7-10 percent in 2009", Migration and Development Brief 10 (Washington, DC: World Bank)

Taylor, J. Edward, Jorge Mora & Richard Adams (2005), "Remittances, Inequality and Poverty: Evidence from Rural Mexico", unpublished manuscript (University of California, Davis)

World Bank (2006), *Cambodia: Halving Poverty by 2015? Poverty Assessment 2006* (East Asia and Pacific Region: World Bank)

World Bank (2008), *Migration and Remittance Factbook 2007* (Washington DC: World Bank)

World Bank (2009), *Poverty Profile and Trends in Cambodia, 2007 - Findings from the Cambodia Socio-Economic Survey (CSES)*, Report No. 48618-KH (East Asia and Pacific Region: World Bank)

World Bank (2010), *Migration and Remittances Factbook 2011* (Washington DC: World Bank